មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្ដីថ្លែងការណ៍
# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាប្រារព្ធទិវានារីអន្តរជាតិ

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤

ទិវានារីអន្តរជាតិ ត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំ នៅថ្ងៃទី០៨ ខែមីនា នៅទូទាំងពិភពលោក ដែលជាការអបអរសាទរចំពោះសមិទ្ធផលនៃការចូលរួមចំណែករបស់ស្ត្រីនៅក្នុងសកម្មភាពសង្គម សេដ្ឋកិច្ច វប្បធម៌ និងនយោបាយ។ ទិវានេះក៏ប្រារព្ធឡើងដើម្បីអំពាវនាវឱ្យមានវិធានការសម្រាប់ការវិនិយោគលើស្ត្រី។ សកម្មភាពគួរឱ្យកត់សម្គាល់ដែលត្រូវបានគេមើលឃើញនៅទូទាំងពិភពលោកនោះ គឺក្រុមនៅតាមមជ្ឈដ្ឋាននានារួបរួមគ្នាដើម្បីលើកកម្ពស់សមភាពយេនឌ័រ ឬការជួបជុំគ្នាដើម្បីធានានូវសេដ្ឋកិច្ចរីកចម្រើន និងយុត្តិធម៌ និងការអភិវឌ្ឍប្រកបដោយចីរភាពសម្រាប់មនុស្សជំនាន់ក្រោយ។ មូលបទសម្រាប់ទិវានារីអន្តរជាតិនៅឆ្នាំ២០២៤ នេះគឺ «**វិនិយោគលើស្ត្រី នាំមកនូវវឌ្ឍនភាពឆាប់រហ័ស**»។

ទិវានារីអន្តរជាតិគឺជាទិវាដ៏សំខាន់ប្រចាំឆ្នាំ ដើម្បីអបអរសាទរអំពីសមិទ្ធផលរបស់ស្ត្រី ការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិរបស់ស្ត្រី និងវិនិយោគដើម្បីវឌ្ឍនភាពរបស់ពួកគេ។ តែយ៉ាងណាក្តី ប្រទេសកម្ពុជានៅតែប្រឈមនឹងសង្គមបិតាធិបតេយ្យដែលបណ្តាលឱ្យមានផ្នត់គំនិតយេនឌ័រ និងបទដ្ឋានសង្គមចាក់គ្រឹះយ៉ាងជ្រៅហេតុធ្វើឱ្យប៉ះពាល់ដល់ការរីកចម្រើនសិទ្ធិស្ត្រី។ ឧទាហរណ៍ ឥរិយាបទប្រមាថមាក់ងាយតាមរយៈពាក្យសម្តីប្រមាថមើលងាយ និងកាយវិការមិនសមរម្យដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ស្ត្រី ជាដើម។ ឥរិយាបថបែបនេះ រារាំងដល់ការសម្រេចបាននូវសមភាពយេនឌ័រ ដោយការបំបិទសំឡេងជនរងគ្រោះ និងជំរុញឱ្យមានវប្បធម៌ស្តីបន្ទោសលើជនរងគ្រោះ។ អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅតែបន្តកើតមានជាច្រើននៅក្នុងប្រទេស ដែលធ្វើឱ្យមានបញ្ហាប្រឈមផងដែរ។

នៅក្នុងឱកាសទិវានារីអន្តរជាតិ ម.ស.ម.ក នឹងរំលេចសកម្មភាពនៃការចូលរួមរបស់ស្ត្រីកម្ពុជានៅក្នុងសង្គមស៊ីវិល និងការងារប្រកបដោយឆន្ទៈដ៏មោះមុតរបស់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី ព្រមទាំងលើកឡើងនូវបរិយាកាសប្រឈមលើអ្នកការពារសិទ្ធិមនុស្សជាស្ត្រី តាមរយៈសកម្មភាពមួយចំនួនដូចខាងក្រោម៖

- នៅថ្ងៃទី០១ និងទី៤ ខែមីនា ឆ្នាំ២០២៤ ម.ស.ម.ក នឹងចេញផ្សាយវីដេអូខ្លីចំនួនពីរអំពីអ្នកការពារសិទ្ធិមនុស្សជាស្ត្រី គឺ អ្នកនាង សេង ធារី និងកញ្ញា ឈឹម ស៊ីថរ។
- នៅថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០២៤ ម.ស.ម.ក នឹងរៀបចំកម្មវិធីវិទ្យុផ្សាយផ្ទាល់លើប្រធានបទ «ឥទ្ធិពលស្ត្រី»។

- ចាប់ពីថ្ងៃទី០៤ ដល់ទី១១ ឆ្នាំ២០២៤ ម.ស.ម.ក នឹងបង្ហោះសារផ្តល់កម្លាំងចិត្តចំនួន ៨ ពីអ្នកការពារសិទ្ធិមនុស្ស និងអ្នកសារព័ត៌មានជាស្ត្រី។
- នៅថ្ងៃទី០៨ ដល់ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៤ ម.ស.ម.ក នឹងចេញផ្សាយនូវសម្រង់ខ្លឹមសារនៃកិច្ចពិភាក្សាវិទ្យុដែលរៀបចំឡើងថ្ងៃទី០៦ ខែមីនា។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក ហួន ផន អ្នកសម្របសម្រួលគម្រោងគាំពារប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពមូលដ្ឋាននៅកម្ពុជា ម.ស.ម.ក តាមរយៈទូរស័ព្ទ៖ +៨៥៥ (០)៧០ ៧៥៧ ៨៨៤ អ៊ីម៉ែល៖phorn@cchrcambodia.org៕

**– ចប់ –**

**<u>បណ្ណាធិការ៖</u>**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») បង្កើតឡើងក្នុងឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធដែលធ្វើការដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅព្រះរាជាណាចក្រកម្ពុជា។

ម.ស.ម.ក ជាសមាជិកនៃដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (IFEX) បណ្តាញសកលដើម្បីសេរីភាពខាងការបញ្ចេញមតិ និងសម្ព័ន្ធពិភពលោកដើម្បីការចូលរួមពលរដ្ឋ (CIVICUS) ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម (OMCT) ជាសមាជិក OECD-Watch ជាសមាជិកនៃបណ្តាញប្រឆាំងទារុណកម្ម អែស អូ អែស និងសម្ព័ន្ធសារព័ត៌មានអាស៊ីអាគ្នេយ៍ (SEAPA) ផងដែរ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ជាជ័យលាភីដែលបានទទួលពានរង្វាន់មូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ស្ថិតក្នុងប្រភេទ «សិទ្ធិ និងសេរីភាព» និងជាជ័យលាភីទទួលពានរង្វាន់ក្នុងឆ្នាំ២០១៣ ផ្នែកទំនាក់ទំនងដើម្បីផ្លាស់ប្តូរសង្គមមកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងការផ្លាស់ប្តូរសង្គមនៅសាកលវិទ្យាល័យឃ្វីនស្លែន ក្នុងទីក្រុងប្រ៊ីសបេន ប្រទេសអូស្ត្រាលី៕